# មូលនិធិដាំដុះ

## ឆ្នាំ ២០២១

សិល្បៈខ្មែរអមតៈមានសេចក្តីរីករាយ នឹងប្រកាសមូលនិធិ “ដាំដុះ” សម្រាប់គម្រោង ដល់សិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌។

មូលនិធិសម្រាប់គម្រោងនេះ គឺបង្កើតឡើងដើម្បីជួយសិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ក្នុងការៈ

- អភិវឌ្ឍគម្រោងច្នៃប្រឌិតថ្មីៗ
- គម្រោងសិល្បៈសហគមន៍
- គម្រោងស្រាវជ្រាវទាក់ទងទៅនឹងសិល្បៈវប្បធម៌កម្ពុជា

ជាពិសេស ពួកយើងចង់គាំទ្រដល់អ្នកដែលមិនធ្លាប់ទទួលបានឱកាសបែបនេះពីមុនមក។ គោលបំណងរយៈពេលវែងនៃ មូលនិធិ “ដាំដុះ” សម្រាប់គម្រោង គឺដើម្បីជួយអភិវឌ្ឍវិស័យសិល្បៈក្នុងប្រទេសកម្ពុជា ដែលផ្តោតសំខាន់ជាពិសេសទៅលើ គំនិតច្នៃប្រឌិត និងភាពជាអ្នកដឹកនាំ។

សិល្បៈខ្មែរអមតៈ ប្តេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានការរើសអើងអំពីអាយុ ពិការភាព ជនជាតិដើមភាគតិច ភេទ អត្តសញ្ញាណភេទ ស្ថានភាពគ្រួសារ សាសនា និងសង្គមសេដ្ឋកិច្ចឡើយ។ យើងសូមលើកទឹកចិត្តជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ ដែលមានសម្លេងតិច ហើយយើងនឹងផ្តល់ការគាំទ្រ (អាស្រ័យលើតម្រូវការ និងភាពចាំបាច់) ទៅដល់បេក្ខជន ដែលទទួលបានការជោគជ័យទាំងនោះ។ យើងអាចកែសម្រួលពាក្យស្នើសុំផងដែរ។

នៅក្នុងយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំរបស់យើង (២០១៧-២០២១) ក៏បានបញ្ជាក់ពីការអភិវឌ្ឍភាពច្នៃប្រឌិត, ការតស៊ូមតិ, និងការបង្កើតថ្មីផងដែរ។ តួនាទីរបស់ពួកយើងជាកត្តាជំរុញ ដែលជួយសិល្បករអាចបង្ហាញ និងផ្សារភ្ជាប់ខ្លួនគេជាមួយនឹងសង្គម, ហើយយើងទាំងអស់គ្នាអាចបង្កើតជាលទ្ធផលវិជ្ជមានមួយសម្រាប់ប្រទេសកម្ពុជាតាមរយៈសិល្បៈ។ មូលនិធិសម្រាប់គម្រោងនេះ គឺជាការចូលរួមចំណែក ដើម្បីបង្កើនឱកាសដល់សហគមន៍សិល្បៈ ក្នុងការបង្កើតការងារ ឬស្នាដៃថ្មី ព្រមទាំងបង្កើតគម្រោង បណ្តាញ និងចំណេះដឹងថ្មី។

មូលនិធិសម្រាប់គម្រោងនេះគឺជា មូលនិធិសម្រាប់គម្រោង៖

| មូលនិធិសម្រាប់គម្រោង | |
|---|---|
| តើ **មូលនិធិសម្រាប់គម្រោង** គឺជាអ្វី? | វាជាប្រភេទមូលនិធិសម្រាប់ ផ្តល់ការគាំទ្រទៅលើ៖<br>- គម្រោងសិល្បៈច្នៃប្រឌិត<br>- គម្រោងសិល្បៈសហគមន៍ ដូចជា ថ្នាក់បង្រៀនសិល្បៈ ឬក៏សកម្មភាពសិល្បៈផ្សេងទៀតនៅក្នុងសហគមន៍<br>- គម្រោងស្រាវជ្រាវពីសិល្បៈ និងវប្បធម៌នៅកម្ពុជា ដូចជា ការស្រាវជ្រាវលើប្រវត្តិសិល្បៈ, ការស្រាវជ្រាវនរវិទ្យាផ្នែកវប្បធម៌, គោលនយោបាយវប្បធម៌ ។ល។ |
| តើនរណាអាចស្នើសុំមូលនិធិនេះបាន? | - សិល្បករ និងអ្នកជំនាញផ្នែកសិល្បៈ<br>- អ្នកស្រាវជ្រាវ និស្សិត អ្នកនិពន្ធ និង អ្នកធ្វើវិវេចនា<br>- សមាជិកក្នុងសហគមន៍ |
| ផុតកំណត់ទទួលពាក្យ | ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០២០ |
| រយៈពេលនៃគម្រោង | គម្រោងត្រូវចាប់ផ្តើម និងបញ្ចប់ ក្នុងចន្លោះខែមករា និងខែធ្នូ ឆ្នាំ ២០២១ |
| ចំនួនប្រាក់ឧបត្ថម្ភ | រហូតដល់ ២៥០០ ដុល្លារអាមេរិក (ចំណាំ៖ មូលនិធិភាគច្រើនទទួលបានប្រាក់ឧបត្ថម្ភពីចន្លោះ៥០០ - ១៥០០ដុល្លារអាមេរិក) |
| ទីតាំងនៃគម្រោង | គម្រោងត្រូវអនុវត្តនៅក្នុងប្រទេសកម្ពុជា |

## លក្ខខណ្ឌជ្រើសរើស៖

មូលនិធិទាំងនេះ គឺសម្រាប់អ្នកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា លិខិតឆ្លងដែន ឬទិដ្ឋាការ K Visa។[1]

ទម្រង់នៃការស្នើសុំ៖

[1] បុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ មិនអាចដាក់ពាក្យស្នើសុំមូលនិធិនេះទេ។

- ត្រូវតែជាពាក្យស្នើសុំរបស់អង្គការសិល្បៈខ្មែរអមតៈ។ សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចដែលបានតម្រូវឲ្យមាន។ ពាក្យស្នើសុំ អាចជាភាសាខ្មែរ ឬអង់គ្លេស។
- ពាក្យស្នើសុំ អាចបំពេញដោយដៃ ឬដោយកុំព្យូទ័រ។ ប្រសិនបើបេក្ខជនមានភាពលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកលេខទូរស័ព្ទ ០៩៣ ៥០៣ ៣៦០ ។
- អាចធ្វើឡើងដោយបុគ្គលម្នាក់ ឬជាក្រុម។ ក្នុងករណីជាក្រុម ត្រូវបញ្ជាក់ឈ្មោះតែប្រធានក្រុម ឬអ្នកតំណាងក្រុម។
- ត្រូវបង្ហាញពីៈ
  - ការប្ដេជ្ញាចិត្តក្នុងការអនុវត្តគម្រោងរបស់អ្នក
  - ចំណាប់អារម្មណ៍របស់អ្នក, ប្រវត្តិនៃការអប់រំ និងការងារក្នុងវិស័យសិល្បៈ និងវប្បធម៌
  - ចក្ខុវិស័យនៃគម្រោងរបស់អ្នក ថាតើគម្រោងរបស់អ្នកនឹងជួយដល់ការអភិវឌ្ឍវិស័យសិល្បៈដោយរបៀបណា។

ការស្នើសុំ **មូលនិធិសម្រាប់គម្រោង** ទៅលើការងារអភិវឌ្ឍភាពច្នៃប្រឌិតៈ

- ត្រូវបង្ហាញពីបទពិសោធន៍ និងប្រវត្តិរូបរបស់បេក្ខជនជាសិល្បករកម្ពុជា ឬ ជាអ្នកធ្វើការក្នុងវិស័យសិល្បៈ
- អាទិភាព នឹងត្រូវផ្ដល់ជូនដល់ទម្រង់សិល្បៈល្ខោន និងតន្ត្រី

**ដំណើរការនៃការជ្រើសរើសៈ**

បេក្ខភាពជ័យលាភីនឹងត្រូវបានជ្រើសរើសដោយគណៈកម្មការ ដែលក្នុងនោះរួមមានដៃគូសហការនៃអង្គការសិល្បៈខ្មែរអមតៈ (ដូចជា មន្ត្រីមកពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬសាកល វិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឬអង្គការសិល្បៈ)។ បុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ នឹងចូលរួមជួយសម្របសម្រួលដំណើរការនៃការជ្រើសរើស តែមិនមានសម្លេងក្នុងការជ្រើសរើសឡើយ។ ចំនួននៃគណៈកម្មការអាស្រ័យទៅតាមប្រភេទនៃការស្នើសុំមូលនិធិ និងឯកទេស។

បេក្ខជនដែលទទួលបានជោគជ័យពីមូលនិធិសម្រាប់គម្រោង នឹងត្រូវប្រកាសលទ្ធផលក្នុងខែធ្នូ ឆ្នាំ ២០២០។ ចំណែកឯបេក្ខជន ដែលទទួលបានជោគជ័យពីមូលនិធិចល័ត នឹងត្រូវប្រកាសលទ្ធផលជូន រាល់ពេលមូលនិធិសម្រាប់គម្រោងនីមួយៗ ត្រូវបានជ្រើសរើស។

សម្រាប់ការផ្ញើពាក្យស្នើសុំ ឬព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់លេខ ០៨៦ ៨៩ ៥៥ ៥៦ ឬ **chandaly@cambodianlivingarts.org**។ (ចន្ទ-សុក្រ ម៉ោង ៨ព្រឹក-៥ល្ងាច)

បញ្ជាក់ៈ ក្រៅពីមូលនិធិ «ដាំដុះ» សម្រាប់គម្រោង យើងនៅមាន **មូលនិធិដាំដុះចល័ត**។ ប៉ុន្តែ **មូលនិធិចល័ត** នឹងត្រូវផ្អាកជាបណ្ដោះអាសន្ន រហូតដល់មានការជូនដំណឹងជាថ្មី! ព័ត៌មានបន្ថែមសូមទាក់ទង sokim@cambodianlivingarts.org ឬ ០៧០ ៥៩ ៦០ ៧៦។